លេខ ៥៥ ចេញផ្សាយថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦

# ព្រឹត្តិបត្រព័ត៌មាន

## ប្រចាំខែមករា ឆ្នាំ២០២៦

## មាតិកា


- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៨.................................... ទំព័រទី ១
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.).. ទំព័រទី ២
- សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចជូនដល់ វីរកងទ័ពជួរមុខនៅមណ្ឌលសុខភាព ចំនួន ២ ទីតាំងគោលដៅ ស្ថិតនៅក្នុង ភូមិសាស្ត្រខេត្តព្រះវិហារ.................................................................. ទំព័រទី ២
- សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ស្តីពីការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ (PEFA) និងការវាយតម្លៃការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ................................................................ ទំព័រទី ២
- មន្ត្រីជំនាញរបស់ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ អេស ប៊ី អាយ លី ហ្វូ ម.ក.................................................................. ទំព័រទី ៣
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំ ឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤.................................................................. ទំព័រទី ៣
- កម្មវិធីបណ្តុះបណ្តាលស្តីពី "នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណ និងសកម្មភាពអាជីវកម្ម នៃក្រុមហ៊ុនបរធនបាល" .................................................... ទំព័រទី ៣
- សិក្ខាសាលា "ច្បាប់ស្តីពីបរធនបាលកិច្ច" ............................................ ទំព័រទី ៤
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារបន្ត ទំព័រទី ៤
- សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងប្រចាំឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦"............................................ ទំព័រទី ៤
- សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ស៊ីស៊ីយូ ខមមើសល ប៉ែង ម.ក.................................................................. ទំព័រទី ៥
- ពិភាក្សាការងាររវាង ន.ប.ធ. ជាមួយគណៈប្រតិភូនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ................................................................ ទំព័រទី ៥
- កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់...................... ទំព័រទី ៦
- ថ្នាក់ដឹកនាំនៃ ន.ប.ធ. ទទួលជួបពិភាក្សាជាមួយប្រតិភូវិនិយោគិន...................... ទំព័រទី ៦
- កម្មវិធីសិក្ខាសាលាស្តីពី "ការបូកសរុបសមិទ្ធផលក្នុងវិស័យបរធនបាលកិច្ច ឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦" .................................. ទំព័រទី ៦
- សិក្ខាសាលាប្រមូលធាតុចូលស្តីពី "បញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ"............... ទំព័រទី ៧
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោង ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" ................................................ ទំព័រទី ៧
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោង ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" ................................................ ទំព័រទី ៨
- កិច្ចប្រជុំពិគ្រោះយោបល់បឋម ប្រចាំឆ្នាំ២០២៦ ជាមួយក្រុមបេសកកម្មការិយាល័យ ស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក ៣ (AMRO) ................................ ទំព័រទី ៨
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍.................................................................. ទំព័រទី ៨
- កិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងជំនួយបច្ចេកទេស (TA) របស់ អ.ស.ហ. ................................................................ ទំព័រទី ៩
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.................................................................. ទំព័រទី ៩
  កម្មវិធី"សម្ពោធអគារថ្មី នៃសាលាបឋមសិក្សា ត្រពាំងព្រីងខេត្តមណ្ឌលគិរី"........... ទំព័រទី ៩
- មហា សន្និបាតបូកសរុបការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៥ និងលើក ទិសដៅការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៦"...................................... ទំព័រទី ១០
- កិច្ចប្រជុំស្តីពី "កិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សា គណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.)"...................................... ទំព័រទី ១០
- សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល"........................................ ទំព័រទី ១១
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំចំនួន ២ របស់និយ័តករបរធនបាលកិច្ច.................................................... ទំព័រទី ១១


**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៨

នាព្រឹកថ្ងៃអង្គារ ៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទនៃ **អ.ស.ហ.** និងសមាជិក-សមាជិកា **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ដោយផ្ទាល់នៅទីស្តីការ **អ.ស.ហ.**។

ជាលទ្ធផលនៃកិច្ចប្រជុំ របៀបវារៈចំនួន ៤ របស់ **ន.ប.ធ.** បានទទួលការអនុម័តពីអង្គប្រជុំ ដែលក្នុងនោះមាន ៖ ១-សេចក្តីព្រាងប្រកាសស្តីពី ការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម, ២-សេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច, ៣-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច, និង៤-សេចក្តីព្រាងប្រកាសស្តីពី ការបើកសាខារបស់បរធនបាល ដោយពិនិត្យ និងកែសម្រួលសម្អាតបន្ថែម មុនដាក់ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ចុះហត្ថលេខាដាក់ឱ្យអនុវត្តជាផ្លូវការ។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៨។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃអង្គារ ៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម របស់ **អ.ស.ហ.**" របស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.**, សេចក្តីព្រាងប្រកាសស្តីពី "ការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យអចលនវត្ថុ និងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ដែលមិនអនុវត្តតាមច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម" របស់ **ន.អ.ប.**, និងសេចក្តីព្រាងប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងភ្នាក់ងារគ្រប់គ្រងមូលនិធិ" របស់ **ន.ម.ក.** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា អនុប្រធាន អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចជូនដល់វីរកងទ័ពជួរមុខ នៅមណ្ឌលសុខភាព ចំនួន ២ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ

នៅថ្ងៃពុធ ៤រោច ខែបុស្ស ឆ្នាំម្សាញ់ ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការីបានចុះសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ជូនដល់វីរកងទ័ពជួរមុខដែលបានរងរបួសក្នុងកំឡុងពេលប្រយុទ្ធនៅសមរភូមិ ជាមួយចោរសៀមឈ្លានពានដែនអធិបតេយ្យកម្ពុជា និងកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាព ចំនួន ២ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។

ដំណើរចុះសួរសុខទុក្ខនាពេលនេះ ធ្វើឡើងក្នុងស្មារតីសាមគ្គីជាតិ «ខ្មែរជួយខ្មែរ» និងដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបង្ហាញអោយឃើញពីការដឹងគុណចំពោះវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពកម្ពុជានូវការលះបង់យ៉ាងធំធេងមិនអាចកាត់ថ្លៃបាន ដើម្បីការពារជាតិមាតុភូមិកម្ពុជាពីខ្មាំងសត្រូវ។



រូបភាព៖ សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចជូនដល់វីរកងទ័ពជួរមុខនៅមណ្ឌលសុខភាព ចំនួន ២ ទីតាំងគោលដៅស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។

## សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ស្តីពីការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និងការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាថ្ងៃព្រហស្បតិ៍ ៥រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វិសនា** អគ្គ-នាយករងនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួម

ទំព័រទី២

សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ស្តីពីការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ (PEFA) និងការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងចំនួន៤ ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិត យ៉េត វីណែល** អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន នៅសណ្ឋាគារ សុខា ភ្នំពេញ។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ស្តីពីការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ (PEFA) និងការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## មន្ត្រីជំនាញរបស់ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ អេស ប៊ី អាយ លី ហ្វរ ម.ក

នាព្រឹកថ្ងៃព្រហស្បតិ៍ ៥រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ **លោក រិន វង្សា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃនិយ័តករបរធនបាលកិច្ច** (**ន.ប.ធ.**) បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ អេស ប៊ី អាយ លី ហ្វរ ម.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។




រូបភាព៖ មន្ត្រីជំនាញរបស់ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ អេស ប៊ី អាយ លី ហ្វរ ម.ក។

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

នាព្រឹកថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦,ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិត យ៉េត វីណែល អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន-អង្គភាព នៅសណ្ឋាគារ រ៉ាហ្វល ឡឺ រ៉ូយ៉ាល់។



រូបភាព៖ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍តាមដាននិងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណ និងសកម្មភាពអាជីវកម្មនៃក្រុមហ៊ុនបរធនបាល"

នាព្រឹក ថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក រិន វង្សា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណ និងសកម្មភាពអាជីវកម្មនៃក្រុមហ៊ុនបរធនបាល" នៅអគារធនាគារជាតិនៃកម្ពុជា (សែនសុខ) ក្នុងគោលបំណងចែករំលែកចំណេះដឹង និង

ទំព័រទី៣

និងបទពិសោធការងារពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ជូនដល់មន្ត្រីជំនាញរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏ដូចជា ដើម្បីបង្កើនប្រសិទ្ធភាពការងារប្រឆាំងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម (AML/CFT) ក្នុងវិស័យបរធនបាលកិច្ច និងសម្រាប់ការត្រៀមខ្លួនទទួលរងការវាយតម្លៃអញ្ញមញ្ញនៅឆ្នាំ២០២៨ របស់ព្រះរាជាណាចក្រកម្ពុជា។



រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណ និងសកម្មភាពអាជីវកម្មនៃក្រុមហ៊ុនបរធនបាល"។

## សិក្ខាសាលា "ច្បាប់ស្តីពីបរធនបាលកិច្ច"

នាថ្ងៃអាទិត្យ ៨រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាអធិបតីក្នុងសិក្ខាសាលា "ច្បាប់ស្តីពីបរធនបាលកិច្ច" អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** ជាវាគ្មិន ដែលសហការរៀបចំដោយ **ន.ប.ធ.** និងវិភាគទានច្បាប់ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងឱ្យកាន់តែទូលំទូលាយ និងស៊ីជម្រៅបន្ថែមលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច ដល់សិស្សចៅក្រម សិស្សព្រះរាជអាជ្ញា អ្នកវិជ្ជាជីវៈច្បាប់ និងសិស្សនិស្សិតដែលជាសមាជិកវិភាគទានច្បាប់សរុបចំនួន ១៨៥ នាក់។



រូបភាព៖ សិក្ខាសាលា "ច្បាប់ស្តីពីបរធនបាលកិច្ច"។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ ២០២៥ និងទិសដៅការងារបន្ត

នាថ្ងៃអង្គារ ១០រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែមករា ២០២៦ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំ "កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាព **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ ឯកឧត្តម/លោកអគ្គនាយករង លោក/លោកស្រីប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** និងមន្ត្រីនៃ **ន.ប.ធ.** ទាំងអស់ នៅសណ្ឋាគារ Sea Breeze Hotel & Villa ខេត្តព្រះសីហនុ។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋាននៃ **ន.ប.ធ.** អំពីសមិទ្ធផលការងារក្នុងឆ្នាំ២០២៥ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើចំណុចខ្លាំង, ចំណុចខ្សោយ, បញ្ហាប្រឈម, កាលានុវត្តភាព និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រ ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅឆ្នាំបន្ទាប់ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។



រូបភាព៖ កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារបន្ត។

## សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងប្រចាំឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ **ន.ប.ធ.** និងជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំសិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងប្រចាំ

ឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មុី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជានាយកគម្រោង ACSEP-PIU1** នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិភាក្សាអំពីលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០២៥ បញ្ហាប្រឈម កាលានុវត្តភាព និងដំណោះស្រាយ ដែលបានអនុវត្តកន្លងមក និងសំណូមពរនានារបស់ស្ថាប័ន/អង្គភាពពាក់ព័ន្ធ ក្នុងដំណើរការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៥ ដើម្បីឈានទៅរកដំណោះស្រាយសមស្របរួមគ្នាមួយសម្រាប់ការរៀបចំយុទ្ធសាស្ត្រអនុវត្តឱ្យបានកាន់តែល្អប្រសើរសម្រាប់ឆ្នាំ២០២៦។ សិក្ខាសាលានេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមកពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB), តំណាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, អង្គភាពអនុវត្តគម្រោង ACSEP-PIU2 & PIU3, តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC), តំណាងគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារទាំង ៦ រួមមាន៖ ធនាគារវីង, ធនាគារប្រៃសណីយ៍កម្ពុជា, ធនាគារហ្វីលីព ភីអិលស៊ី, អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា និងតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តគោលដៅទាំង ១៤។



រូបភាព៖ សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងប្រចាំឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦"។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ស៊ីស៊ីយូ ខេមមើសល ប៊ែង ម.ក

នាព្រឹកថ្ងៃពុធ ១១រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក រិន រដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ស៊ីស៊ីយូ ខមមើសល ប៊ែង ម.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ស៊ីស៊ីយូ ខមមើសល ប៊ែង ម.ក។

## កិច្ចពិភាក្សាការងាររវាង ន.ប.ធ. ជាមួយគណៈប្រតិភូនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

នាព្រឹកថ្ងៃសុក្រ ១៣ រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករង នៃ **ន.ប.ធ.** អមដោយសហការី បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូនៃបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) តំណាងដោយ **លោក គាត ពុធណារិទ្ធិ ប្រធាននាយកដ្ឋានគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម** ក្នុងគោលបំណងដើម្បីស្វែងយល់អំពីចក្ខុវិស័យ បេសកកម្ម បេនាសម្ព័ន្ធ និងផែនការយុទ្ធសាស្ត្ររបស់និយ័តករបរធនបាលកិច្ច។ ជាលទ្ធផលនៃការជួបពិភាក្សាភាគីទាំងពីរនឹងបន្តទំនាក់ទំនងជាមួយគ្នាដើម្បីស្វែងយល់ពីគ្នាឱ្យកាន់តែស៊ីជម្រៅព្រមទាំងបន្ទីតិវិធីការងារដែលអាចមានជាមួយគ្នា។



រូបភាព៖ កិច្ចពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយគណៈប្រតិភូនៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។

## កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់

នារសៀលថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** អមដោយសហការី បានជួបប្រជុំជាមួយប្រតិភូវិភាគទានច្បាប់ ដឹកនាំដោយ **លោកស្រីមេធាវី ទេព បូផល ស្ថាបនិកវិភាគទានច្បាប់** និងលោក/លោកស្រីមេធាវី សហអ្នកនិពន្ធ ក្នុងគោលបំណងដើម្បីបន្តពិភាក្សាការងារលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច ដែលពាក់ព័ន្ធនឹងការធ្វើសន្តតិកម្ម ក្នុងន័យទទួលបានជាតុចូលបន្ថែមលើការរៀបចំការសរសេរសៀវភៅ "នីតិសន្តតិកម្ម" នៅទីស្តីការនៃ **ន.ប.ធ.**។



រូបភាព៖ កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់។

## ថ្នាក់ដឹកនាំនៃ ន.ប.ធ. ទទួលជួបពិភាក្សាជាមួយប្រតិភូវិនិយោគិន

នាព្រឹកថ្ងៃចន្ទ ១កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបពិភាក្សាជាមួយប្រតិភូវិនិយោគិន ដែលដឹកនាំដោយ **លោក Liu Yi Chuan អនុប្រធានគ្រុបអភិវឌ្ឍន៍ឧស្សាហកម្ម AIM** ដែលមានចំណាប់អារម្មណ៍វិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាស្វែងយល់ពីកាលានុវត្តភាពនៃការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ច។



រូបភាព៖ ថ្នាក់ដឹកនាំនៃ ន.ប.ធ. ទទួលជួបពិភាក្សាជាមួយប្រតិភូវិនិយោគិន។

## កម្មវិធីសិក្ខាសាលាស្តីពី "ការបូកសរុបសមិទ្ធផលក្នុងវិស័យបរធនបាលកិច្ចឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦"

នាព្រឹកថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ **ន.ប.ធ.** បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី "ការបូកសរុបសមិទ្ធផលក្នុងវិស័យបរធនបាលកិច្ចឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយកម្មវិធីនេះមានការអញ្ជើញចូលរួមពីតំណាងសមាគមបរធនបាលកម្ពុជា ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ពិនិត្យរួមគ្នាអំពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជាដល់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធ, ការទទួលជាតុចូលអំពីទស្សនវិស័យចំពោះនិន្នាការនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ច បញ្ហាប្រឈម និងសំណូមពរនានាពីប្រតិបត្តិករនៅក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា ព្រមទាំងទិសដៅយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២៦។

កម្មវិធីនេះ ក៏មានការប្រគល់លិខិតថ្លែងអំណរគុណដល់បរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ដែលបានចូលរួមចលនាសាមគ្គីជាតិ "ខ្មែរជួយខ្មែរ" និងដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឧបត្ថម្ភដល់វីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែន តាមរយៈនិយ័តករបរធនបាលកិច្ច ផងដែរ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** កម្មវិធីសិក្ខាសាលាស្តីពី "ការបូកសរុបសមិទ្ធផលក្នុងវិស័យបរធនបាលកិច្ច ឆ្នាំ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦"។

## សិក្ខាសាលាប្រមូលធាតុចូលស្តីពី "បញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ"

នាថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ចេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមសិក្ខាសាលាប្រមូលធាតុចូលស្តីពី "បញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ" ក្រោមអធិបតីភាពរបស់ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភសហាវ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.** ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** និងថ្នាក់ដឹកនាំមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ នៅសណ្ឋាគារ អករូតព្រីមៀ ភ្នំពេញ។



**រូបភាព៖** សិក្ខាសាលាប្រមូលធាតុចូលស្តីពី "បញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ"។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" សម្រាប់ខេត្តព្រៃវែង នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង** ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **លោក ជុំ ច័ន្ទតារា អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង**។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសនោះ គោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះនិងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិក-សមាជិកានៃសហគមន៍កសិករ ដែលស្ថិតនៅខេត្តព្រៃវែង ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយតំណាងសមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana



**រូបភាព៖** សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី"។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម ដល់រដ្ឋបាលខេត្តគោលដៅថ្មី"

នាព្រឹកថ្ងៃសុក្រ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី" សម្រាប់ខេត្តស្វាយរៀង នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម សុខ រស់** អភិបាលរងខេត្ត តំណាង **ឯកឧត្តម ម៉េង ពោធិ៍សា អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង**។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសនោះ គោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិក-សមាជិកានៃសហគមន៍កសិករ ដែលស្ថិតនៅខេត្តស្វាយរៀង ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយតំណាងសមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ដល់រដ្ឋបាលខេត្តគោលដៅថ្មី"។

## កិច្ចប្រជុំពិគ្រោះយោបល់បឋម ប្រចាំឆ្នាំ២០២៦ ជាមួយក្រុមបេសកកម្មការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក ៣ (AMRO)

នារសៀលថ្ងៃសុក្រ ៥ កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦ **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក រិន រដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់បឋម ប្រចាំឆ្នាំ២០២៦ ជាមួយក្រុមបេសកកម្មការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក ៣ (AMRO) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



**រូបភាព៖** កិច្ចប្រជុំពិគ្រោះយោបល់បឋម ប្រចាំឆ្នាំ២០២៦ ជាមួយក្រុមបេស-កកម្មការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក ៣ (AMRO)។

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

នារសៀលថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម**

ទំព័រទី៨

**សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបពិភាក្សាជាមួយ **ឯកឧត្តម បណ្ឌិត ទ្រី សុផល** អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសហការី ពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ចសាធារណៈ។



**រូបភាព៖** កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## កិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងជំនួយបច្ចេកទេស (TA) របស់ អ.ស.ហ.

នារសៀលថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងជំនួយបច្ចេកទេស (TA) របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដែលផ្តល់ការគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការអនុវត្តសកម្មភាពគោលនយោបាយ (Policy Actions) ដែលបានកំណត់ក្នុង "Policy-Based Loan - Subprogram 2 - Inclusive and Sustainable Finance Development Program" ជាមួយក្រុមការងារអនុវត្តគម្រោង TA នៃធនាគារ ADB នៅទីស្តីការ **អ.ស.ហ.**។



**រូបភាព៖** កិច្ចប្រជុំពិភាក្សាក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងជំនួយបច្ចេកទេស (TA) របស់ **អ.ស.ហ.**។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃពុធ ១០កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** អគ្គនាយករង និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៥ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## កម្មវិធី "សម្ពោធអគារថ្មី នៃសាលាបឋមសិក្សា ត្រពាំងព្រីង ខេត្តមណ្ឌលគិរី"

នាព្រឹកថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមអមជាគណៈអធិបតីក្នុងកម្មវិធី"សម្ពោធអគារថ្មី នៃសាលាបឋមសិក្សាត្រពាំងព្រីង ខេត្តមណ្ឌលគិរី" ដែលឧបត្ថម្ភ និងសាងសង់ដោយបរធន

នៃបរធនបាលកិច្ចសង្គម អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពី **ឯកឧត្តម ដាក់ ម៉េងហ៊ាង** អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី, **បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិនៃធនាគារ អេស៊ីលីដាភីអិលស៊ី** និងលោកបណ្ឌិត **ព្រំ វិសុទ្ធ ប្រធានអង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ** ព្រមទាំងមានការចូលរួមពីគណៈប្រតិភូអមដំណើរឯកឧត្តមរដ្ឋមន្ត្រី លោកនាយករងរដ្ឋបាលសាលាខេត្ត លោកលោកស្រីប្រធាន-អនុប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ ជាផ្លូវការស្រុក ឃុំ លោកគ្រូ-អ្នកគ្រូ ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ។

ពិធីនេះប្រព្រឹត្តទៅនៅបរិវេណសាលាបឋមសិក្សាត្រពាំងព្រីង ភូមិចំរើន ឃុំស្រែកសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី។



*រូបភាព៖ កម្មវិធី "សម្ពោធអគារថ្មី នៃសាលាបឋមសិក្សា ត្រពាំងព្រីង ខេត្តមណ្ឌលគិរី"។*

## មហាសន្និបាតបូកសរុបការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៥ និងលើកទិសដៅការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៦"

នៅរសៀលថ្ងៃពុធ ១០កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុង "មហាសន្និបាតបូកសរុបការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៥ និងលើកទិសដៅការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៦" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។




*រូបភាព៖ មហាសន្និបាតបូកសរុបការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៥ និងលើកទិសដៅការងារសភាពាណិជ្ជកម្មកម្ពុជាឆ្នាំ២០២៦"។*

## កិច្ចប្រជុំស្តីពី "កិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.)"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី "កិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (**គ.ក.គ.ក.**)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ទី តាយី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ព្រមទាំងមានការចូលរួមពីសមាជិកទីប្រឹក្សា និងលេខាធិការដ្ឋានរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា នៅទីស្តីការ **កសហវ**។



*រូបភាព៖ កិច្ចប្រជុំស្តីពី "កិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.)"។*

## សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល"

នារសៀលថ្ងៃព្រហស្បតិ៍ ១១កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៦ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់ក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** សំដៅដល់ការធានាលើប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងទទួលបានទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះ មានការចូលរួមពីតំណាងសមាគមបរធនបាលកម្ពុជា, ក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច។




រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល"។

## សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំចំនួន ២ របស់និយ័តករបរធនបាលកិច្ច

នារសៀលថ្ងៃសុក្រ ១២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំចំនួន ២ រួមមាន៖ សេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "វិធានប្រតិបត្តិការរបស់បរធនបាល" និងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "យន្តការនៃការស្នើសុំបង្កើត ចុះបញ្ជី បន្តសុពលភាពវិញ្ញាបនបត្រ ផ្លាស់ប្តូរ និងបញ្ចប់បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកតាមប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចរបស់ **ន.ប.ធ.**" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីបរធនបាល ដែលជាអនុវត្តការងារផ្ទាល់ ដើម្បីឱ្យការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំទាំងពីរខាងលើ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះ មានការចូលរួមពីតំណាងសមាគមបរធនបាលកម្ពុជា, ក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក បរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។




រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំចំនួន ២ របស់និយ័តករបរធនបាលកិច្ច។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888